ថ្ងៃពុធ ទី១៥ កក្កដា ២០២៦

**ចំណោទទី១** មាន $2026$ ចំនួនគត់ធំជាង $1$ មិនចាំបាច់ផ្សេងគ្នាពីរៗ សរសេរលើតារាងមួយ។ នៅនាទីនីមួយៗ ណូអេមី ជ្រើសរើសចំនួនគត់ពីរ $m > 1$ និង $n > 1$ ចេញកន្លែងផ្សេងគ្នានៃតារាង និងជំនួសចំនួនទាំងនេះដោយពីរចំនួនគត់

$$gcd(m,n) \qquad \text{និង} \qquad \frac{lcm(m,n)}{gcd(m,n)}$$

ណូអេមីបន្តធ្វើការផ្លាស់ចំនួនដែលគាត់អាចធ្វើទៅបាន។

1. បង្ហាញថាទោះជាការជ្រើសរើសរបស់ណូអេមីយ៉ាងណាក៏ដោយ ក្រោយការប្តូរច្រើនកំណត់ មានចំនួនគត់ $M$ តែមួយគត់នៅលើតារាង ធំជាង $1$ ។
2. បង្ហាញថាតម្លៃនៃ $M$ មិនអាស្រ័យនឹងការជ្រើសរើសរបស់ណូអេមីទេ។

សម្គាល់៖ យើងកំណត់យក $gcm(x,y)$ តាងតួចែករួមធំបំផុតនៃចំនួនគត់វិជ្ជមាន $x$ និង $y$ រួច $lcm(x,y)$ តាងពហុគុណរួមតូចបំផុតនៃ $x$ និង $y$ ។

**ចំណោទទី២** $ABC$ ជាត្រីកោណមួយ។ $M$ និង $N$ រៀងគ្នា ជាចំណុចកណ្តាលនៃជ្រុង $AB$ និង $AC$ ។ ចំណុច $K$ និង $L$ ត្រូវបានជ្រើសរើស រៀងគ្នា នៅខាងក្នុងដាច់ខាត ត្រីកោណ $BMC$ និង $BNC$ ដែល $K$ នៅខាងក្នុងដាច់ខាត ត្រីកោណ $ABL$ និង $L$ នៅខាងក្នុងដាច់ខាត ត្រីកោណ $AKC$ ។ ឧបមាថា

$$\angle KBA = \angle ACL, \qquad \angle LBK = \angle LNC, \qquad \text{និង} \qquad \angle LCK = \angle BMK$$

យក $O$ ជាផ្ចិតរង្វង់ចារិកក្រៅត្រីកោណ $AKL$ ។ បង្ហាញថា $OM = ON$ ។

**ចំណោទទី៣** $n$ ជាចំនួនគត់វិជ្ជមានដាច់ខាត។ ខេមរា និងធីតា មានដំបងមួយមានប្រវែង $1$ និងចង់ចែកដំបងគ្នាជាកំណាត់ៗ។ ខេមករា ក្រិតយ៉ាងច្រើន $n$ ចំណុចនៅលើដំបង និង ធីតាក្រិតយ៉ាងច្រើន $n$ ចំណុចនៅលើដំបង។ ចំណុចក្រិតទាំងអស់ផ្សេងៗគ្នាពីរៗ។ គាត់ទាំងពីរនាក់ កាត់ដំបងត្រង់ចំណុចក្រឹត ដែលបង្កើតបានចំនួនមួយនៃកំណាត់ដំបងតូចៗ។ បន្ទាប់មកដោយធ្វើម្តងម្នាក់ ដោយចាប់ផ្តើមពីខេមរា រួចធីតា ដែលដល់វេនជ្រើសរើសកំណាត់ដំបងដែលមិនទាន់បានជ្រើសរើស។ គោលបំណងនៃអ្នកលេងល្បែងនីមួយៗគឺធ្វើអតិបរិមាកម្មផលបូកសរុបនៃប្រវែងកំណាត់ដំបងតូចៗនៃដំបងដែលបានជ្រើសរើស។
ចំពោះគ្រប់ $n$ កំណត់តម្លៃធំបំផុត $c$ ដែលខេមា ធានាបានប្រវែងដំបងសរុប $c$ យ៉ាងតិច ទោះជាការជ្រើសរើសរបស់ធីតាយ៉ាងណាក៏ដោយ។

:

រយៈពេល ៖ ៤ ម៉ោង ៣០នា
ចំណោទនីមួយៗទទួលបាន៧ ពិន្ទុ

ថ្ងៃព្រហស្បតិ៍ ទី១៦ កក្កដា ២០២៦

**ចំណោទទី៤** សានយូ និង មូឡាន លេងល្បែងមួយ។ $\theta$ ជាចំនួនពិតផ្ទៀងផ្ទាត់ $0^\circ < \theta < 180^\circ$ ដែលអ្នកលេងល្បែងទាំងពីរត្រូវស្គាល់។ នៅដំបូង សានយូ បង្កើតត្រីកោណ $T$ មួយដែលមានទម្រង់ចង់បាន។ បន្ទាប់មក នៅនាទីនីមួយៗ សានយូ និង មូឡាន ធ្វើការផ្លាស់ប្តូររូបរាងខាងក្រោម៖

- បើត្រីកោណ $T$ មានយ៉ាងតិច មុំមួយមានរង្វាស់ $\theta$ គិតជាដឺក្រេ នោះល្បែងត្រូវបញ្ចប់ និង មូឡាន ឈ្នះ។
- បើមិនមែនករណីនេះទេ មូឡាន ជ្រើសរើសចំណុច $P$ មួយនៅលើជ្រុងមួយនៃជ្រុងនៃ $T$ ផ្សេងពីកំពូលទាំងបីនៃត្រីកោណ $T$ ។ បន្ទាប់មក គាត់កាត់ត្រីកោណតាមបន្ទាត់ត្រង់រវាងចំណុច $P$ និងកំពូលឈមនឹង $P$ ក្នុងត្រីកោណ $T$ ដែលបង្កើតបានត្រីកោណក្រដាស់ពីរ។
- សានយូ ចោលត្រីកោណមួយនៃត្រីកោណទាំងពីរ។ ត្រីកោណដែលនៅសល់ក្លាយជាត្រីកោណថ្មី ហៅ $T$ ដដែល។

តើចំពោះតម្លៃនៃចំនួនពិត $\theta$ ណាដែល មូឡាន ធានាឈ្នះនៅពេលកំណត់ ទោះជា សានយូ លេងល្បែងយ៉ាងណាក៏ដោយ ?

**ចំណោទទី៥** យក $\mathbb{R}_{>0}$ ជាសំណុំចំនួនពិតវិជ្ជមានដាច់ខាត។ កំណត់អនុគមន៍ $f\colon \mathbb{R}_{>0} \to \mathbb{R}_{>0}$ ទាំងអស់ដែលផ្ទៀងផ្ទាត់

$$\sqrt{\frac{x^2+f(y)^2}{2}} \geqslant \frac{f(x)+y}{2} \geqslant \sqrt{xf(y)}$$

ចំពោះគ្រប់ $x, y \in \mathbb{R}_{>0}$ ។

**ចំណោទទី៦** $a_1, a_2, a_3, \ldots$ ជាស្វ៊ីតមិនកំណត់នៃចំនួនគត់វិជ្ជមានធំជាង $1$ ។ ឧបមថា ចំពោះគ្រប់ចំនួនគត់វិជ្ជមាន $n$ ចំនួន $a_{n+1}$ ជាចំនួនគត់វិជ្ជមានតូចបំផុត ធំជាង $a_n$ ដែល $gcd(a_{n+1}, a_i) > 1$ ចំពោះ $i = 1, 2, \ldots, n$ ។
បង្ហាញថាមានចំនួនគត់វិជ្ជមាន $T$ និង $L$ ដែល

$$a_{n+T} = a_n + L$$

ចំពោះចំនួនគត់វិជ្ជមាន $n$ ។
កំណត់សម្គាល់៖ $gcd(x, y)$ តាងតួចែករួមធំបំផុតនៃចំនួនគត់វិជ្ជមាន $x$ និង $y$ ។

:

រយៈពេល ៖ ៤ ម៉ោង ៣០នាទី
ចំណោទនីមួយៗទទួលបាន៧ ពិន្ទុ